គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
The National Committee for Sub-National Democratic Development



# សន្និសីទជាតិស្តីពី
# កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៖
# " មេរៀនបទពិសោធន៍ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត "

**ថ្ងៃ៧-៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២១-២២ ខែកុម្ភៈ ឆ្នាំ២០១៨**
**រាជធានីភ្នំពេញ៖ មជ្ឈមណ្ឌលសន្និបាតកោះពេជ្រ**

## របាយការណ៍ស្តីពី
## វឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅ
## នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

1

ការបង្កើតរដ្ឋបាលនៅក្បែរជិតប្រជាពលរដ្ឋ
www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# មាតិកា

- ❖ សារតា
- ❖ វឌ្ឍនភាព
- ❖ បញ្ហាប្រឈម
- ❖ ទិសដៅ
- ❖ សន្និដ្ឋាន

2

ការបង្កើតរដ្ឋបាលនៅក្បែរជិតប្រជាពលរដ្ឋ
www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

## អំពីសារ តា

- ➢ សន្តិភាព
- ➢ ស្ថេរភាពនយោបាយ
- ➢ ការឯកភាពជាតិ
- ➢ ការឯកភាពទឹកដី

**ការស្តារ និងការអភិវឌ្ឍប្រទេសជាតិឡើងវិញ**

គោលនយោបាយជាតិ៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣

- ✓ កំណែទម្រង់រដ្ឋបាលសាធារណៈ/កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ✓ កំណែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- ✓ កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ
- ✓ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

3



## អំពីសារ តា (ត)

- ❑ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាសមាសធាតុដ៏សំខាន់នៃកំណែទម្រង់រដ្ឋបាលសាធារណៈ
- ❑ ផ្តោតលើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមគោលការណ៍រដ្ឋបាលឯកភាព និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ

➡ បង្កើតវប្បធម៌ប្រជាធិបតេយ្យនៅមូលដ្ឋានដោយមានការចូលរួមពីប្រជាពលរដ្ឋ

➡ លើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបតម្រូវការ និងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ

➡ ចូលរួមកាត់បន្ថយភាពក្រីក្រ

4

# អំពីសាវតា (ត)

**ឆ្នាំ ២០០១** | **ឆ្នាំ២០០២ ការផ្លាស់ប្ដូរជាប្រវត្តិសាស្ត្រប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់**

- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សងាត់




- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ (២០០២-២០០៧)



- រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៃឃុំ សង្កាត់
  - ✓ នីតិវិធីការងារ
  - ✓ ប្រព័ន្ធផែនការ
  - ✓ ការបង្កើតមូលនិធិឃុំ សង្កាត់
  - ✓ ប្រព័ន្ធហិរញ្ញវត្ថុ

**លទ្ធផលវិជ្ជមាន៖**

- លទ្ធផលនយោបាយ
- ការផ្ដល់សេវា និងការអភិវឌ្ឍមូលដ្ឋាន៖
  - ✓ គម្រោងហេដ្ឋារចនាសម្ព័ន្ធ
  - ✓ គម្រោងផ្ដល់សេវាសង្គម
  - ✓ គម្រោងបង្កើនប្រាក់ចំណូល
  - ✓ គម្រោងការពារ និងអភិរក្សធនធានធម្មជាតិ

5

ការបង្ខិតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# សាវតា (ត)

**ឆ្នាំ២០០២ ការផ្លាស់ប្ដូរជាប្រវត្តិសាស្ត្រប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់**

ប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់



ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំផែនការ



គម្រោងហេដ្ឋារចនាសម្ព័ន្ធ



គម្រោងបង្កើនប្រាក់ចំណូល



6

ការបង្ខិតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/


អំពីសាវតា (ត)
ឆ្នាំ ២០០៥
ឆ្នាំ២០០៨
ឆ្នាំ២០០៩
ឆ្នាំ២០១០
•ក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
• វិសោធនកម្មរដ្ឋធម្មនុញ្ញ
• ច្បាប់រៀបចំអង្គការ
• ការបោះឆ្នោតក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
• រៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងឡើងវិញ
• កម្មវិធីជាតិរយៈពេល១០ឆ្នាំ
www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/


អំពីសាវតា (ត)
កម្មវិធីជាតិត្រូវបានរៀបចំដើម្បីធ្វើផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់វិមជ្ឈការដោយផ្តោតលើសមាសធាតុសំខាន់ៗ ចំនួន៥៖
ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ត្រូវបានលើកកម្ពស់
២. ការរៀបចំស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ
៣.ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
៤. ការផ្ទេរមុខងារ
៥. វិមជ្ឈការហិរញ្ញវត្ថុ
១. ការគ្រប់គ្រងការងារកំណែទម្រង់
8
www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# អំពីសាវតា (ត)

➢កម្មវិធីជាតិត្រូវបានបែងចែកជា៣ដំណាក់កាលសម្រាប់ការអនុវត្ត៖

| ផអ៣ទី១ ៖ ២០១១-២០១៤ | ផអ៣ទី២ ៖ ២០១៥-២០១៧ | ផអ៣ទី៣៖ ២០១៨-២០២០ |
|---|---|---|
| ការកែសម្រួលរចនាសម្ព័ន្ធ និង ប្រព័ន្ធ និងនីតិវិធីថ្មីៗសម្រាប់ការគ្រប់គ្រង និងការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីកែលំអគុណភាពសេវា និងការអភិវឌ្ឍមូលដ្ឋាន | ការបន្តជំរុញ និងពង្រឹងការទទួលខុសត្រូវ និងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន |

➢ផអ៣ទី១ និងទី២ត្រូវបានអនុវត្តចប់នៅដំណាច់ឆ្នាំ២០១៧



www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# អំពីវឌ្ឍនភាព

• ពាក់ព័ន្ធនឹងការគ្រប់គ្រងការងារកំណែទម្រង់៖

✓យន្តការដឹកនាំ៖ គ.ឃ.ស → គ.ជ.វ.វ → គ.ជ.អ.ប

✓ក្របខ័ណ្ឌគតិយុត្តជាង៣០០ (ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំបច្ចេកទេស)

✓ផអ៣ទី១-ទី២ និងផ.ស.ថ ប្រចាំឆ្នាំ៖ ថវិការដ្ឋប្រមាណជាង២.០០០លានដុល្លា និងថវិកាដៃគូប្រមាណជាង៥៧០លានដុល្លា

✓សម្របសម្រួល និងគាំទ្រក្រសួង ស្ថាប័នចំនួន២១ និងរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស ក្នុងការចូលរួមអនុវត្តកំណែទម្រង់ (ជាង១២លានដុល្លា/ឆ្នាំ)

✓ការបង្កើតយន្តការ និងកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រសួងចំនួន១៤បានចូលរួមកិច្ចដំណើរការផ្ទេរមុខងារ)

✓ការគាំទ្រដល់ការបង្កើតសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (សមាគមន៍ក្រុមប្រឹក្សារាជធានី ខេត្ត និងសម្ព័ន្ធភាពជាតិសមាគមនក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់)

✓ការបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ វាយតម្លៃ និងផ្សព្វផ្សាយព័ត៌មាន (ប្រព័ន្ធត្រួតពិនិត្យជាប្រចាំលើការអនុវត្ត ផ.ស.ថ ប្រចាំឆ្នាំ ការអង្កេតអភិបាលកិច្ច២ឆ្នាំម្តង ការគ្រប់គ្រងប្រព័ន្ធទិន្នន័យមូលដ្ឋាន និងយុទ្ធសាស្រ្តផ្សព្វផ្សាយព័ត៌មាន)



www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# អំពីវឌ្ឍនភាព (ត)

- ពាក់ព័ន្ធនឹងការរៀបចំស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិ៖

✓ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ (៤អាណត្តិ)

✓ ការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២អាណត្តិ)

✓ ការកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

✓ ការតែងតាំង និងធ្វើសមាសហរណកម្មបុគ្គលិកឱ្យទៅបំពេញការងារក្នុងរចនាសម្ព័ន្ធថ្មី

✓ ការបង្កើតនីតិវិធីការងារ និងប្រព័ន្ធគ្រប់គ្រង(នីតិវិធីប្រជុំក្រុមប្រឹក្សា ពិគ្រោះយោបល់សាធារណៈ ប្រព័ន្ធផែនការ គ្រប់គ្រងហិរញ្ញវត្ថុ ត្រួតពិនិត្យនីត្យានុកូលភាព ទំនាក់ទំនងអន្តររដ្ឋាន...)

✓ ការពង្រឹងខ្សែគណនេយ្យភាពតាមបែបប្រជាធិបតេយ្យរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

✓ ការពង្រឹងយន្តការគាំទ្របច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់

✓ ការលើកកម្ពស់យេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមទៅក្នុងនីតិវិធី និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

✓ ការរៀបចំ និងអនុវត្តការងារគណនេយ្យភាពសង្គមដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធនឹងប្រើប្រាស់ថវិកា និងការអនុវត្តការងារឃុំ សង្កាត់ ការផ្តល់សេវារបស់សាលាបឋមសិក្សា និងមណ្ឌលសុខភាព (អនុវត្តនៅឃុំគោលដៅចំនួន៧៣១ឃុំ)





# អំពីវឌ្ឍនភាព (ត)

- ពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ៖

✓ ការរៀបចំលិខិតគតិយុត្តសម្រាប់ការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- អនុក្រឹត្យធ្វើប្រតិភូកម្មអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិក
- គោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ព្រះរាជក្រមស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- សេចក្តីណែនាំនានាស្តីពីនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

✓ ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អំពីក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានអនុវត្ត និងអំពីក្របខ័ណ្ឌនៃការអនុវត្តការងារ តាមរយៈវគ្គបណ្តុះបណ្តាល ការហ្វឹកហាត់ការងារ ការធ្វើផងរៀនផង សិក្ខាសាលា (វគ្គបណ្តុះបណ្តាលជាង២៥០វគ្គ ក្រុមប្រឹក្សា និងបុគ្គលិកចំនួន២៨៤.៥៩៥នាក់)

✓ ការរៀបចំបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន ដែលជាយន្តការអចិន្ត្រៃយ៍ក្នុងការផ្តល់សេវាអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

# អំពីវឌ្ឍនភាព (ត)

• ពាក់ព័ន្ធនឹងការផ្ទេរមុខងារ៖

✓ការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចដំណើរការផ្ទេរមុខងារ៖

- អនុក្រឹត្យស្តីពីកិច្ចដំណើរការទូទៅនៃការផ្ទេរមុខងារ
- សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំបញ្ជីវិភាគមុខងារ
- សេចក្តីណែនាំស្តីពីការពិនិត្យមើលមុខងារឡើងវិញដើម្បីកំណត់មុខងារសមស្រប និងធនធានជាក់លាក់ដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

✓ក្រសួង ស្ថាប័នចំនួន១៤ បានរៀបចំកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

✓ក្រសួងចំនួន៧បានផ្ទេរជាបណ្តើរៗនូវមុខងារចំនួន២០ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រគល់ និងការធ្វើប្រតិភូកម្ម (បរិស្ថាន សង្គមកិច្ច អភិវឌ្ឍន៍ជនបទ ទេសចរណ៍ អប់រំ ឧស្សាហកម្ម រ៉ែ និងថាមពល)

✓ក្រសួងចំនួន១០បានធ្វើប្រតិភូកម្មមុខងារផ្តល់សេវារដ្ឋបាលចំនួន១២៥ប្រភេទទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការិយាល័យច្រកចេញចូលតែមួយ (ក្រុង ស្រុកចំនួន៥២ ប្រជាពលរដ្ឋចំនួនជាង២លាននាក់ ប្រមូលចំណូលបានជាំង១៤លានដុល្លា)

13

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# អំពីវឌ្ឍនភាព (ត)

• ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖

✓ការរៀបចំច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

✓ការរៀបចំលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការបង្កើតមូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុក ការគ្រប់គ្រង និងប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ ការចែករំលែកចំណូលព័ន្ធ និងសារពើព័ន្ធ

✓ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន

✓ផ្ទេរថវិការដ្ឋជាង២.០០០លានដុល្លាទៅឱ្យថ្នាក់ក្រោមជាតិ

- ឃុំ សង្កាត់ជាង៦០៩លានដុល្លា (ឆ្នាំ២០០២-២០១៧)
- ក្រុង ស្រុកជាង១១១លានដុល្លា (២០១៣-២០១៧)
- រាជធានីខេត្តជាង១.២៨១លានដុល្លា(២០០៩-២០១៧)

✓រដ្ឋបាលក្រោមជាតិបានប្រើប្រាស់ថវិកាទាំងនេះក្នុងការផ្តល់សេវានិងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងផ្តល់សេវាសង្គមប្រមាណ១.៨០០គម្រោងក្នុង១ឆ្នាំៗ)

✓ការរៀបចំប្រព័ន្ធផែនការ និងអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកសាងផែនការ

14

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# អំពីបញ្ហាប្រឈម

ទោះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក៏មានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ៖

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាមទារនូវការប្ដេជ្ញាចិត្តខាងនយោបាយរយៈពេលវែង និងតម្រូវឱ្យមានការផ្លាស់ប្ដូរឥរិយាបថ និងទម្លាប់ក្នុងការគ្រប់គ្រងនៅគ្រប់ថ្នាក់ និងគ្រប់វិស័យក្នុងការកំណត់ និងបែងចែកឡើងវិញនូវមុខងារ ធនធាន ការទទួលខុសត្រូវ និងស្វ័យភាពរវាងរដ្ឋបាលនានានៅថ្នាក់ក្រោមជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយក្រសួង ស្ថាប័ននានា។ ក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធីជាតិ៖

- ✓ ក្រសួង ស្ថាប័នមួយចំនួននៅពុំទាន់ស្រុះស្រួលមូលគំនិតគ្នាទាំងស្រុងអំពីការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសក្នុងក្របខ័ណ្ឌនៃស្វ័យភាព និងការទទួលខុសត្រូវក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ✓ ក្រសួង ស្ថាប័នមួយចំនួននៅតែមានភាពស្ទាក់ស្ទើរក្នុងការសម្រេចចិត្តផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

15

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# អំពីបញ្ហាប្រឈម (ត)

ការចំណាយសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់តាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនាពេលកន្លងមក ពឹងផ្អែកលើធនធានចូលរួមរបស់ដៃគូអភិវឌ្ឍន៍នានា។ ដើម្បីធានាដល់ការដឹកនាំការងារកំណែទម្រង់ប្រកបដោយនិរន្តរភាព តម្រូវឱ្យមានការ៖

- ✓ ពង្រឹងភាពជាម្ចាស់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការដាក់បញ្ចូលនូវសកម្មភាពស្នូលនៃកំណែទម្រង់នេះទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នសាមីនីមួយៗ ដោយប្រើប្រាស់ថវិការដ្ឋតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រ៉ាប់រងលើការចំណាយក្នុងការអនុវត្តសកម្មភាពស្នូលនៃកំណែទម្រង់ទាំងនោះ។

16

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# អំពីបញ្ហាប្រឈម (ត)

ដើម្បីធានាដល់ការអនុវត្តកំណែទម្រង់ចាប់ពីដំណាក់កាលដំបូងៗមកដល់បច្ចុប្បន្ន មានលិខិតបទដ្ឋានជាច្រើនបានរៀបចំ និងដាក់ឱ្យអនុវត្ត ដែលក្នុងនោះ៖

- ✓លិខិតបទដ្ឋានមួយចំនួនត្រូវបានរៀបចំដោយពុំបានសម្របសម្រួលគ្នា
- ✓លិខិតបទដ្ឋានមួយចំនួនត្រូវបានរៀបចំដោយពុំបានផ្អែកលើប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ និងច្បាប់រៀបចំអង្គការ
- ✓លិខិតបទដ្ឋានខ្លះទៀតមានលក្ខណៈសាំញ៉ាំធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិពិបាកយល់ និងមិនអាចអនុវត្តបាន

ប្រការនេះតម្រូវឱ្យមានការពិនិត្យឡើងវិញដើម្បីកែសម្រួលឱ្យមានលក្ខណៈស៊ីសង្វាក់គ្នា ស្របតាមប្រព័ន្ធគ្រប់គ្រង    វិមជ្ឈការ និងវិសហមជ្ឈការ ដែលកំណត់ដោយច្បាប់រៀបចំអង្គការ និងរៀបចំលិខិតបទដ្ឋានឲ្យកាន់តែមានលក្ខណៈសាមញ្ញ ងាយយល់ និងងាយស្រួលក្នុងការអនុវត្តជាក់ស្តែងនៅតាមមូលដ្ឋាន។

17

ការបង្ខិតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# អំពីបញ្ហាប្រឈម (ត)

- ✓រចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់ឆ្លើយតបទៅនឹងការវិវឌ្ឍ និងការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងសង្គមនៅតាមតំបន់ជាក់លាក់នានា
- ✓ពុំទាន់បានកំណត់ និងបែងចែកឱ្យបានច្បាស់លាស់នូវតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមប្រភេទ ឬចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះឡើយ (ប្រព័ន្ធគ្រប់គ្រងទីក្រុងធំៗ ទីក្រុង/ទីប្រជុំជន) ដែលកំពុងមានការកើនឡើងយ៉ាងលឿន និងកំពុងជួបប្រទះបញ្ហាប្រឈមនានាកាន់តែច្រើនឡើងៗ

តម្រូវឱ្យមានការសិក្សាកែសម្រួលរចនាសម្ព័ន្ធនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់ឱ្យបានច្បាស់លាស់អំពី៖

- ✓តួនាទីរបស់រដ្ឋបាលខេត្តធ្វើជាតំណាងឱ្យរាជរដ្ឋាភិបាលក្នុងការតាមដានត្រួតពិនិត្យ ការផ្តល់ការគាំទ្របច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
- ✓តួនាទីរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ជាដែលរដ្ឋបាលមូលដ្ឋានមានតួនាទីផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ។

18

ការបង្ខិតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

## អំពីបញ្ហាប្រឈម (ត)

✓យន្តការអធិការកិច្ចលើការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅពុំទាន់បានរៀបចំដោយមានសុខដុមនីយកម្មរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅឡើយ។ ប្រការនេះតម្រូវឱ្យមានការសិក្សា និងរៀបចំយន្តការធ្វើអធិការកិច្ច ឬការវាយតម្លៃប្រចាំឆ្នាំលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធានាដល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមលទ្ធផលនៃការបំពេញការងារតាមស្តង់ដា និងសូចនាករដែលបានកំណត់

✓ភាពយឺតយ៉ាវនៃការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាបញ្ហាប្រឈមក្នុងការផ្ទេរ និងការជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពឱ្យទៅបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

✓តម្រូវឱ្យមានការរៀបចំនូវប្រព័ន្ធលើកទឹកចិត្ត ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅតំបន់ជនបទអាចស្រូបទាញបាននូវធនធានមនុស្សដែលមានគុណភាព សមត្ថភាពសម្រាប់បម្រើការងារ

19

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/
ការបង្វិលរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

## អំពីបញ្ហាប្រឈម (ត)

ទោះបីមុខងារមួយចំនួនត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិហើយក៏ដោយ ក៏រដ្ឋបាលថ្នាក់ក្រោមជាតិនៅពុំទាន់មានលទ្ធភាព និងសមត្ថភាពពេញលេញក្នុងការអនុវត្តមុខងារទាំងនោះនៅឡើយ ដោយសារ ៖

✓ក្រសួង ស្ថាប័នមួយចំនួនពុំទាន់បានរៀបចំផ្ទេរនូវធនធានហិរញ្ញវត្ថុ និងធនធានមនុស្សឱ្យបានសមស្រប

✓ក្រសួង ស្ថាប័នមួយចំនួនមានភាពយឺតយ៉ាវក្នុងការរៀបចំលិខិតបទដ្ឋាន និងស្តង់ដាសម្រាប់អនុវត្តមុខងារ

✓ក្រសួង ស្ថាប័នមួយចំនួនបានផ្ទេរមុខងារដែលភ្ជាប់មកជាមួយនូវគោលការណ៍ បែបបទ និងនីតិវិធីសាំញ៉ាំ ស្មុគស្មាញដែលធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិលំបាកស្វែងយល់ក្នុងការអនុវត្ត

✓ក្រសួង ស្ថាប័នមួយចំនួនពុំទាន់បានរៀបចំផែនការសកម្មភាព និងកម្មវិធីច្បាស់លាស់សម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានផ្ទេរទាំងនោះ។

20

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/
ការបង្វិលរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

## អំពីបញ្ហាប្រឈម (ត)

✓រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ពុំទាន់មានធនធានសមស្របសម្រាប់បំពេញមុខងាររបស់ខ្លួនឱ្យបានពេញលេញនៅឡើយ ទោះបីជាទំហំនៃមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់មានការកើនឡើងជាលំដាប់ក៏ដោយ

✓បែបបទ នីតិវិធីសម្រាប់ការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ក៏នៅមានភាពស្មុគស្មាញ សាំញ៉ាំ និងការិយាធិបតេយ្យ ដែលពុំទាន់ធានាដល់ការពង្រឹងស្វ័យភាព និងឆន្ទានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដែលបានធ្វើឱ្យការប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះមិនអាចសម្រេចបានតាមផែនការ និងការអនុវត្តគម្រោងប្រចាំឆ្នាំនានាមានភាពយឺតយ៉ាវ។

21

ការបង្កើតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

## អំពីទិសដៅ

**ទី១៖** បន្តពង្រឹងការគ្រប់គ្រងការងារកំណែទម្រង់ ដើម្បីធានាលើកកម្ពស់ភាពជាម្ចាស់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដឹកនាំ សម្របសម្រួល គ្រប់គ្រង និងអនុវត្តកំណែទម្រង់ ព្រមទាំងបន្តពង្រឹងកិច្ចសហការក្នុងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជនដើម្បីកៀរគរការចូលរួម និងគាំទ្រដល់កំណែទម្រង់នេះឱ្យកាន់តែមានភាពសកម្ម និងរស់រវើកបន្ថែមទៀត

**ទី២៖** បន្តពង្រឹង កែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយកំណត់នូវតួនាទី និងការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់តាមប្រភេទ និងចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ។ បន្តពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកទឹកចិត្ត និងផ្តល់ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាការងារដែលបានកំណត់ឱ្យកាន់តែបានល្អប្រសើរឡើង។

22

ការបង្កើតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# អំពីទិសដៅ (ត)

**ទី៣៖** បន្តលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធនមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនឡើងឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិក។ បន្តកែលម្អវិធីសាស្ត្រអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការរៀបចំ និងដាក់ឱ្យដំណើរការនូវសាលាជាតិរដ្ឋបាលមូលដ្ឋាន និងស្ថាប័នអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈអចិន្ត្រៃយ៍ និងជាប្រព័ន្ធអភិវឌ្ឍសមត្ថភាពដែលមានកម្មវិធី និងស្តង់ដាជាក់លាក់។ ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តោតទៅលើការបណ្តុះនូវគំនិតផ្តួចផ្តើមប្រកបដោយភាពច្នៃប្រឌិតថ្មីៗ និងជំនាញជាក់លាក់ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានស្របតាមស្តង់ដា ស្ថានភាព និងតម្រូវការជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ។

23

ការបង្កើតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh

www.facebook.com/ncdds/

# អំពីទិសដៅ (ត)

**ទី៤៖** បន្តជំរុញការផ្ទេរមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើសក្នុងវិស័យអាទិភាពនានាទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវការផ្ទេរសិទ្ធិអំណាច ការទទួលខុសត្រូវ ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងសមត្ថភាពជាក់លាក់ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាព និងសមត្ថភាពក្នុងការគ្រប់គ្រង ចាត់ចែងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដោយផ្ទាល់ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ជាមួយគ្នានេះ យន្តការផ្តល់សេវាតាមច្រកចេញចូលតែមួយនឹងត្រូវបន្តពង្រឹង និងពង្រីកទៅគ្រប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទាំងអស់ទូទាំងប្រទេស ដើម្បីបង្កលក្ខណៈកាន់តែងាយស្រួលជូនប្រជាពលរដ្ឋក្នុងការទទួលបានសេវាឆាប់រហ័ស តម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព។

24

ការបង្កើតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ

www.ncdd.gov.kh
db.ncdd.gov.kh

www.facebook.com/ncdds/

# អំពីទិសដៅ (ត)

**ទី៥៖** បន្តជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ដើម្បីធានាដល់ការបង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងធនធានជាឆន្ទានុសិទ្ធិ និងធនធានមានភ្ជាប់លក្ខខណ្ឌ ព្រមទាំងបន្តកែលម្អប្រព័ន្ធ នីតិវិធី និងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុ និងសមត្ថភាពសមស្របក្នុងការគ្រប់គ្រងចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះ ដើម្បីផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បន្តខិតខំបង្កើនអត្រាចូលរួមធនធានពីថវិការដ្ឋទៅក្នុងមូលនិធិឃុំ សង្កាត់ពី២,៨%នៅឆ្នាំ២០១៨ទៅ៣%នៅឆ្នាំ២០២៣ និងបង្កើនអត្រាចូលរួមធនធានពីថវិការដ្ឋទៅក្នុងមូលនិធិក្រុង ស្រុកពី១%នៅឆ្នាំ២០១៨ទៅ៣,៥%នៅឆ្នាំ២០២៣។

25

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

# អំពីសេចក្តីសន្និដ្ឋាន

- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានអនុវត្តចាប់ពីឆ្នាំ២០០១មក បានបង្កើតនូវសមិទ្ធផលជាច្រើនពាក់ព័ន្ធទៅនឹងការកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍នៃរដ្ឋបាលឯកភាពការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋ។
- សមិទ្ធផលជាង១ទសវត្សរ៍កន្លះមកនេះបង្ហាញឱ្យឃើញថា កំណែទម្រង់នេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមនានានៅមូលដ្ឋាន ព្រមទាំងបានចូលរួមលើកស្ទួយជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព បរិយាប័ន្ន និងសមធម៌សង្គម។

26

www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/

គជអប NCDD
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
The National Committee for Sub-National Democratic Development

# សូមអរគុណ!

27

ការបង្កើតរដ្ឋបាលនៅកៀកជិតប្រជាពលរដ្ឋ
www.ncdd.gov.kh
db.ncdd.gov.kh
www.facebook.com/ncdds/